01049267

E319/7

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 24 / 12 / 2014
ម៉ោង (Time/Heure) : 15:20
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
**Case File/Dossier No. 002/19-09-2007-ECCC/TC**

| | |
|---|---|
| ចំពោះមុខ: | ចៅក្រម **និល ណុន** ជាប្រធាន |
| | ចៅក្រម Jean-Marc LAVERGNE |
| | ចៅក្រម **យ៉ា សុខន** |
| | ចៅក្រម Claudia FENZ |
| | ចៅក្រម **យូរ ឧត្តរា** |
| កាលបរិច្ឆេទ: | ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៤ |
| ភាសាដើម: | ខ្មែរ/អង់គ្លេស/បារាំង |
| ចំណាត់ថ្នាក់ឯកសារ: | សាធារណៈ |

# សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំឲ្យទទួលយកឯកសារ ដែលទាក់ទងនឹងសហករណ៍ត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់ និងសេចក្តីបង្គាប់ ស្តីពីការប្រើប្រាស់កំណត់ហេតុនៃការស្តាប់ចម្លើយក្នុងសំណុំរឿង ០០៣ និង ០០៤

**សហព្រះរាជអាជ្ញា**

ជា លាង
Nicholas KOUMJIAN

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ
Marie GIRAUD

**ជនជាប់ចោទ**

នួន ជា
ខៀវ សំផន

**មេធាវីជនជាប់ចោទ**

សុន អរុណ　Athur VERCKEN
Victor KOPPE　Anta GUISSÉ
គង់ សំអុន

E319/7

## ១. សេចក្ដីផ្ដើម

១. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានអនុញ្ញាតឱ្យមានការបង្ហាញកំណត់ហេតុនៃការស្ដាប់ចម្លើយដែលជាឯកសារសម្ងាត់ចំនួន ៣៣ និងឧបសម្ព័ន្ធមួយភ្ជាប់ទៅនឹងកំណត់ហេតុនៃការស្ដាប់ចម្លើយមួយ ក្នុងចំណោមកំណត់ហេតុនៃការស្ដាប់ចម្លើយសម្ងាត់ទាំងនេះ[1]។ កំណត់ហេតុនៃការស្ដាប់ចម្លើយទាំងនេះ ទទួលបានពីបុគ្គលចំនួន ២៦ នាក់ ក្នុងអំឡុងកិច្ចស៊ើបសួរដែលកំពុងដំណើរការក្នុងសំណុំរឿង ០០៤[2]។ នៅពេលនេះ អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំឱ្យទទួលយកជាភ័ស្តុតាង នូវកំណត់ហេតុនៃការស្ដាប់ចម្លើយចំនួន ៣០ ក្នុងចំណោមកំណត់ហេតុនៃការស្ដាប់ចម្លើយទាំងនេះ ដែលទទួលបានពីបុគ្គលចំនួន ២៥ នាក់ រួមជាមួយនឹងឧបសម្ព័ន្ធដែលទាក់ទងនឹងសហករណ៍ត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់[3]។ កំណត់ហេតុនៃការស្ដាប់ចម្លើយដែលពាក់ព័ន្ធ មានបង្ហាញនៅក្នុងតារាងមួយដែលភ្ជាប់មកជាមួយនឹងសំណើតាមវិធាន ៨៧ នៃវិធានផ្ទៃក្នុង[4]។

២. អង្គជំនុំជម្រះសាលាដំបូង ក៏បានទទួលសំណើមួយពីសហព្រះរាជអាជ្ញាអន្តរជាតិផងដែរ ដែលស្នើឡើងនូវនីតិវិធីដើម្បីប្រើប្រាស់កំណត់ហេតុនៃការស្ដាប់ចម្លើយទាំងនេះ ក្នុងអំឡុងពេលសវនាការក្នុងសំណុំរឿង ០០២/០២។ នីតិវិធីដែលបានស្នើឡើងនេះ ក៏មានបំណងសម្រាប់យកមកអនុវត្តចំពោះកំណត់ហេតុនៃ

---

[1] ដីកាសម្រេចលើ *សំណើជាបន្ទាន់របស់សហព្រះរាជអាជ្ញាសុំដាក់បង្ហាញនូវកំណត់ហេតុស្ដាប់ចម្លើយសាក្សីនៃសំណុំរឿង ០០៤ ដែលទាក់ទងនឹងវគ្គទី១ នៃការជំនុំជម្រះក្ដីនៅក្នុងសំណុំរឿង ០០២/០២* ឯកសារ E319.2 ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១៤ ("ដីកាសម្រេចលើសំណើសុំដាក់បង្ហាញកំណត់ហេតុស្ដាប់ចម្លើយ")។ សូមមើល ផងដែរ ការដាក់បង្ហាញកំណត់ហេតុនៃសំណុំរឿង ០០៤ របស់សហព្រះរាជអាជ្ញាអន្តរជាតិ ឯកសារ E319 ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៤ ("ការដាក់បង្ហាញកំណត់ហេតុរបស់សហព្រះរាជអាជ្ញា")។

[2] ដីកាសម្រេចលើសំណើសុំដាក់បង្ហាញកំណត់ហេតុស្ដាប់ចម្លើយ កថាខណ្ឌ ២៣។ សូមមើល ផងដែរ ឧបសម្ព័ន្ធ ក ភ្ជាប់ជាមួយនឹងការដាក់បង្ហាញកំណត់ហេតុរបស់សហព្រះរាជអាជ្ញា៖ បញ្ជីកំណត់ហេតុស្ដាប់ចម្លើយសាក្សីនៃសំណុំរឿង ០០៤ ដែលបានស្នើឡើងដើម្បីដាក់បង្ហាញនៅក្នុងសំណុំរឿង ០០២ អនុលោមតាម CF004-D193/4 ឯកសារ E319.1 ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៤។

[3] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំឱ្យទទួលយកឯកសារដែលទាក់ទងនឹងសហករណ៍ត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់ អនុលោមតាម វិធាន ៨៧(៣) និង ៨៧(៤)នៃវិធានផ្ទៃក្នុង ឯកសារ E319/5 ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ("សំណើតាមវិធាន ៨៧")។

[4] ឧបសម្ព័ន្ធ ង - ចម្លើយរបស់សាក្សីថ្មី ទាក់ទិននឹងសហករណ៍ត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់ ឯកសារ E319/5.1 ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៤។

ការស្តាប់ចម្លើយដែលជាឯកសារសម្ងាត់ពីក្នុងសំណុំរឿង ០០៣ និង ០០៤ ដែលសហចៅក្រមស៊ើបអង្កេត អាចអនុញ្ញាតឱ្យមានការដាក់បង្ហាញនៅក្នុងសំណុំរឿង ០០២/០២ នៅពេលអនាគត[5]។

## ២. ឧទ្ទិករណ៍

### ២.១ សំណើតាមវិធាន ៨៧

៣. នៅក្នុងការគាំទ្រសំណើតាមវិធាន ៨៧ របស់ខ្លួន សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា កំណត់ហេតុនៃការស្តាប់ចម្លើយនីមួយៗដែលបានស្នើឡើង បំពេញនូវលក្ខណៈវិនិច្ឆ័យគ្រប់គ្រាន់សម្រាប់ការទទួលយក ដូចមានចែងនៅក្នុងវិធាន ៨៧(៣) និង ៨៧(៤) នៃវិធានផ្ទៃក្នុង[6]។ សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា កំណត់ហេតុនៃការស្តាប់ចម្លើយទាំងនេះជាប់ពាក់ព័ន្ធយ៉ាងខ្លាំងទៅនឹងទីតាំងឧក្រិដ្ឋកម្មនៅសហករណ៍ត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់[7]។ សហព្រះរាជអាជ្ញាអន្តរជាតិកត់សម្គាល់ផងដែរថា កំណត់ហេតុនៃការស្តាប់ចម្លើយទាំងអស់នេះ ត្រូវបានធ្វើឡើងនៅក្នុងឆ្នាំ ២០១៣ ឬ ឆ្នាំ ២០១៤ បន្ទាប់ពីការចាប់ផ្តើមជំនុំជម្រះក្នុងសំណុំរឿង ០០២ ហើយថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ទើបតែបានអនុញ្ញាតឱ្យខ្លួន ផ្តល់កំណត់ហេតុនៃការស្តាប់ចម្លើយទាំងនេះជូនមកអង្គជំនុំជម្រះសាលាដំបូងនៅពេលថ្មីៗនេះប៉ុណ្ណោះ គឺនៅថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១៤[8]។

៤. អង្គជំនុំជម្រះសាលាដំបូង ពុំបានទទួលសារណាតបទៅនឹងសំណើតាមវិធាន ៨៧ នេះឡើយ។

### ២.២ នីតិវិធីដែលបានស្នើឡើងដើម្បីប្រើប្រាស់កំណត់ហេតុនៃការស្តាប់ចម្លើយក្នុងសំណុំរឿង ០០៣ និង ០០៤ នៅក្នុងសវនាការ

---

[5] សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ស្តីពីនីតិវិធីដែលបានស្នើឡើងដើម្បីប្រើប្រាស់កំណត់ហេតុស្តាប់ចម្លើយសាក្សីនៃសំណុំរឿង ០០៣ និង ០០៤ ឯកសារ E319/2 ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១៤ ("នីតិវិធីដែលបានស្នើឡើង")។

[6] សំណើតាមវិធាន ៨៧ កថាខណ្ឌ ២។ ឧបសម្ព័ន្ធ ង ដែលភ្ជាប់ជាមួយនឹងសំណើតាមវិធាន ៨៧ ផ្តល់នូវការពិពណ៌នាអំពី ឯកសារនីមួយៗក្នុងចំណោមឯកសារចំនួន ៣១ ដែលបានដាក់ជូន។

[7] សំណើតាមវិធាន ៨៧ កថាខណ្ឌ ២។

[8] សំណើតាមវិធាន ៨៧ កថាខណ្ឌ ៣។ ដីកាសម្រេចលើសំណើសុំដាក់បង្ហាញកំណត់ហេតុស្តាប់ចម្លើយ កថាខណ្ឌ ២៣-២៤។

៥. នៅក្នុងដីកាសម្រេចលើសំណើសុំដាក់បង្ហាញកំណត់ហេតុនៃការស្ដាប់ចម្លើយ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានអនុញ្ញាតឱ្យមានការបង្ហាញកំណត់ហេតុនៃការស្ដាប់ចម្លើយដែលជាឯកសារសម្ងាត់ពីក្នុងសំណុំរឿង ០០៤ ក្រោមលក្ខខណ្ឌដាក់កំហិតមួយចំនួន[9]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិក៏បានស្នើផងដែរឱ្យអង្គជំនុំជម្រះធានាថា ភាគីទាំងអស់គោរពតាមដីកាសម្រេចលើសំណើសុំបង្ហាញកំណត់ហេតុនៃការស្ដាប់ចម្លើយនេះ[10]។ ការពិភាក្សាបឋមមួយស្ដីអំពីការប្រើប្រាស់នៅពេលសវនាការនូវកំណត់ហេតុនៃការស្ដាប់ចម្លើយដែលមានប្រភពដើមចេញពីសំណុំរឿង ០០៣ និង ០០៤ ត្រូវបានធ្វើឡើងក្នុងអំឡុងកិច្ចប្រជុំរៀបចំសវនាការកាលពីថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៤[11]។

៦. ដើម្បីអនុវត្តតាមលក្ខខណ្ឌដែលបានកំណត់ដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ សហព្រះរាជអាជ្ញាអន្តរជាតិស្នើឡើងថា កំណត់ហេតុនៃការស្ដាប់ចម្លើយក្នុងសំណុំរឿង ០០៣ និង ០០៤ ដែលត្រូវយកមកបង្ហាញសម្រាប់ប្រើប្រាស់នៅក្នុងសំណុំរឿង ០០២/០២ គួរត្រូវបានទទួលយកជាភ័ស្ដុតាង និងចាត់ថ្នាក់ជាឯកសារសម្ងាត់ ដែលអនុវត្តតាមកិច្ចដំណើរការនីតិវិធីសវនាការក្នុងសំណុំរឿង ០០២/០១[12]។ សហព្រះរាជអាជ្ញាអន្តរជាតិស្នើឡើងបន្ថែមទៀតថា ឯកសារកំណត់ហេតុនៃការស្ដាប់ចម្លើយដែលជាឯកសារសម្ងាត់ទាំងនេះ អាចត្រូវបានប្រើប្រាស់នៅក្នុងអំឡុងកិច្ចដំណើរការនីតិវិធីសវនាការជាសាធារណៈក្នុងសំណុំរឿង ០០២/០២ រួមមាន ការសួរដេញដោលសាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណី ដូចនៅក្នុងសំណុំរឿង ០០២/០១ ដែរ[13]។ សហព្រះរាជអាជ្ញាអន្តរជាតិបានផ្ដល់សំណៅនៃនីតិវិធីដែលបានស្នើឡើងនេះមួយច្បាប់

---

[9] ដីកាសម្រេចលើសំណើសុំដាក់បង្ហាញកំណត់ហេតុស្ដាប់ចម្លើយ កថាខណ្ឌ ២៣-២៤។

[10] ដីកាសម្រេចលើសំណើសុំដាក់បង្ហាញកំណត់ហេតុស្ដាប់ចម្លើយ កថាខណ្ឌ ២៣, ២៦។

[11] ប្រតិចារឹក ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៤ ទំព័រ ៤-១៥ (ភាសាអង់គ្លេស)។ មេធាវីការពារក្ដីខកខានពុំបានចូលរួមកិច្ចប្រជុំរៀបចំសវនាការនេះ ជាការរំលោភលើដីកាបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូង។ សូមមើល អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង មានចំណងជើង "ការព្រមានមេធាវីការពារក្ដី នួន ជា និង ខៀវ សំផន" ឯកសារ E320 ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៤។

[12] នីតិវិធីដែលបានស្នើឡើង កថាខណ្ឌ ២-៣។

[13] នីតិវិធីដែលបានស្នើឡើង កថាខណ្ឌ ២។

ជូនទៅសហចៅក្រមស៊ើបអង្កេត[14] ហើយសហចៅក្រមស៊ើបអង្កេតមិនបានបង្ហាញពីការជំទាស់ណាមួយទៅនឹងនីតិវិធីដែលបានស្នើឡើងនេះឡើយ។

៧. មិនមានការដាក់សារណាតបជាលាយលក្ខណ៍អក្សរទៅនឹងនីតិវិធីដែលបានស្នើឡើងនេះឡើយ។ នៅក្នុងកិច្ចប្រជុំរៀបចំសវនាការ ដែលបានធ្វើឡើងនៅថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៤ នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងសួរអំពីការជំទាស់ណាមួយទៅនឹងនីតិវិធីដែលបានស្នើឡើងនោះ មេធាវីការពារក្តី នួន ជា មិនបានបញ្ជាក់អំពីជំហររបស់ខ្លួនឡើយ[15]។ មេធាវីការពារក្តី ខៀវ សំផន បានកត់សម្គាល់ថា នីតិវិធីដែលបានស្នើឡើងនោះ គឺស្រដៀងគ្នាទៅនឹងការអនុវត្តដែលមេធាវីការពារក្តីបានប្តឹងសាទុក្ខនៅក្នុងសំណុំរឿង ០០២/០១ និងបានជំទាស់ទៅនឹងបទប្បញ្ញត្តិដែលបានស្នើឡើង ដែលហាមឃាត់មិនឱ្យមានការយោងទៅលើកំណត់ហេតុនៃការស្តាប់ចម្លើយដែលជាឯកសារសម្ងាត់ មានប្រភពដើមពីសំណុំរឿង ០០៣ ឬ ០០៤ នៅក្នុងអំឡុងពេលសវនាការជាសាធារណៈឡើយ។ មេធាវីការពារក្តី ខៀវ សំផន ពុំបានបញ្ជាក់ពីការជំទាស់ផ្សេងទៀតឡើយ[16]។

## ៣. ច្បាប់ជាធរមាន

៨. រាល់ភ័ស្តុតាងទាំងអស់គឺអាចទទួលយកបាន[17] និងដោយគោរពតាមលក្ខណៈវិនិច្ឆ័យដែលមានចែងនៅក្នុងវិធាន ៨៧(៣) និង (៤) នៃវិធានផ្ទៃក្នុង ភាគីអាចស្នើសុំឱ្យអង្គជំនុំជម្រះទទួលយកភ័ស្តុតាងនៅគ្រប់ដំណាក់កាលនៃការជំនុំជម្រះ[18]។ អង្គជំនុំជម្រះមានឆន្ទានុសិទ្ធិទូលំទូលាយក្នុងការកំណត់អំពីការទទួលយកភ័ស្តុតាង[19]។ គ្រប់ភ័ស្តុតាងដែលបានស្នើឡើងទាំងអស់ និងដែលមិនទាន់រកបានទៅក្នុងអំឡុងពេលអង្គជំនុំ-

---

[14] នីតិវិធីដែលបានស្នើឡើង កថាខណ្ឌ ៦។

[15] ប្រតិចារិក ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៤ ទំព័រ ១៧-១៨ (ភាសាអង់គ្លេស)។

[16] ប្រតិចារិក ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៤ ទំព័រ ១៨ (ភាសាអង់គ្លេស)។ មេធាវីការពារក្តី ខៀវ សំផន បានជំទាស់ទៅនឹងកថាខណ្ឌ "៥.១" នៃនីតិវិធីដែលបានស្នើឡើង។ ផ្ទុយទៅវិញ តាមការសន្និដ្ឋាន មេធាវីការពារក្តី ខៀវ សំផន ចង់សំដៅទៅលើកថាខណ្ឌ "៥(ក)" នៃនីតិវិធីដែលបានស្នើឡើង។

[17] វិធាន ៨៧(១) នៃវិធានផ្ទៃក្នុង។

[18] វិធាន ៩(៥) និង (៦), ១០(៤), ៥៥(៦), ៥៥(១១) និងវិធាន ៨៦ នៃវិធានផ្ទៃក្នុង។

[19] សាលក្រម សំណុំរឿង ០០២/០១ ឯកសារ E313 ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ២៥។

ជម្រះទទួលបានសំណុំរឿង ត្រូវចាត់ទុកថាជាភ័ស្តុតាង "ថ្មី" អនុលោមតាមលក្ខខណ្ឌតម្រូវនៃវិធាន ៨៧ (៤) នៃវិធានផ្ទៃក្នុង[20]។

៩. អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូង អាចទទួលយកភ័ស្តុតាងថ្មីនានា ដែលអង្គជំនុំជម្រះចាត់ទុកថាមានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត នៅពេលដែលភ័ស្តុតាងនោះបំពេញតាមបទដ្ឋាន*ការបញ្ជាក់បឋម*នៃភាពពាក់ព័ន្ធ ភាពអាចជឿជាក់បាន និងយថាភាពដែលតម្រូវដោយវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។ ភាគីស្នើសុំត្រូវធ្វើឱ្យអង្គជំនុំជម្រះជឿជាក់ថា ភ័ស្តុតាងដែលខ្លួនស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះ មិនអាចរកបាននៅមុនពេលនៃការចាប់ផ្តើមជំនុំជម្រះ ឬមិនអាចត្រូវបានរកឃើញកាលពីពេលមុននេះ ដោយមានការយកចិត្តទុកដាក់ត្រឹមត្រូវក៏ដោយ[21]។ មុនពេលដាក់ភ័ស្តុតាងថ្មីចូលទៅក្នុងសំណុំរឿង អង្គជំនុំជម្រះត្រូវសម្រេចថាតើភ័ស្តុតាងថ្មីនេះមានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិតដែរ ឬទេ[22]។ ភាគីត្រូវតែមានឱកាសក្នុងការដាក់ភ័ស្តុតាងនៅក្នុងកិច្ចពិភាក្សាដេញដោល និងជំទាស់ទៅលើការទទួលយកភ័ស្តុតាងនោះ ទោះបីជាភាគីមិនបានប្រើប្រាស់ឱកាសនេះក្តី[23]។

## ៤. សំអាងហេតុ

### ៤.១ សំណើតាមវិធាន ៨៧

១០. អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា កំណត់ហេតុនៃការស្តាប់ចម្លើយដែលសហព្រះរាជអាជ្ញាបានស្នើឡើង មានភាពពាក់ព័ន្ធតាម*ការបញ្ជាក់បឋម* ដោយសារតែកំណត់ហេតុនៃការស្តាប់ចម្លើយទាំងនេះ ជាប់ពាក់ព័ន្ធដោយផ្ទាល់ទៅនឹងអង្គហេតុនានាដែលត្រូវជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០២ និង

---

[20] សាលក្រម សំណុំរឿង ០០២/០១ ឯកសារ E313 ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ២៥។

[21] សូមមើល ឧទាហរណ៍ សេចក្តីសម្រេចលើសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដោយអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ពាក់ព័ន្ធនឹងសៀវភៅកំណត់ហេតុប្រចាំថ្ងៃក្នុងរបបកម្ពុជាប្រជាធិបតេយ្យរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលមានលេខសម្គាល់ 2-TCC-296 ឯកសារ E323/1 ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០១៤ កថាខណ្ឌ ២។

[22] សេចក្តីសម្រេចទាក់ទិននឹងឯកសារថ្មីៗ និងបញ្ហាពាក់ព័ន្ធដទៃទៀត ឯកសារ E190 ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១២ កថាខណ្ឌ ២៧ ជើងទំព័រ ៣៨។

[23] សាលក្រម សំណុំរឿង ០០២/០១ ឯកសារ E313 ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ២៦។

បំពេញនូវលក្ខណៈវិនិច្ឆ័យតាមវិធាន ៨៧ នៃវិធានផ្ទៃក្នុង។ កំណត់ហេតុនៃការស្តាប់ចម្លើយទាំងនេះ ជាប់ពាក់ព័ន្ធទៅនឹងសហករណ៍ត្រាំកក់ មន្ទីរសន្តិសុខក្រាំងតាចាន់ ការប្រព្រឹត្តិទៅលើក្រុមគោលដៅ ការចេញបទបញ្ជាអំពីការរៀបអាពាហ៍ពិពាហ៍ និងអង្គហេតុផ្សេងៗទៀតដែលត្រូវយកមកជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០២។ ដូច្នេះ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថាការទទួលយកកំណត់ហេតុនៃការស្តាប់ចម្លើយទាំងនេះ មានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត។ កំណត់ហេតុនៃការស្តាប់ចម្លើយទាំងនេះ ត្រូវបានធ្វើឡើងនៅក្នុងឆ្នាំ ២០១៣ ឬ ឆ្នាំ ២០១៤ និងមិនអាចរកបានដើម្បីឱ្យមានការទទួលយកជាភ័ស្តុតាងនោះឡើយ រហូតដល់សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានអនុញ្ញាតឱ្យមានការបង្ហាញកំណត់ហេតុនៃការស្តាប់ចម្លើយទាំងនេះ ដូចបានបញ្ជាក់នៅក្នុងដីកាសម្រេចលើសំណើសុំបង្ហាញកំណត់ហេតុនៃការស្តាប់ចម្លើយ ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១៤[24]។ បន្ទាប់មក សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់សំណើតាមវិធាន ៨៧ របស់ខ្លួនទាន់ពេលវេលា និងបានបញ្ជាក់ថា ភ័ស្តុតាងដែលបានស្នើឡើងនោះមិនអាចរកបានកាលពីមុននេះទេ។ លើសពីនេះទៀតមិនមានភាគីណាមួយជំទាស់ទៅនឹងការទទួលយកកំណត់ហេតុនៃការស្តាប់ចម្លើយទាំងនេះឡើយ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូង នឹងទទួលយកកំណត់ហេតុនៃការស្តាប់ចម្លើយទាំងនេះជាភ័ស្តុតាង។

## ៤.២ នីតិវិធីដែលបានស្នើឡើងដើម្បីប្រើប្រាស់កំណត់ហេតុនៃការស្តាប់ចម្លើយនៃសំណុំរឿង ០០៣ និង ០០៤ នៅក្នុងសវនាការ

១១. សហចៅក្រមស៊ើបអង្កេត ធ្លាប់បានអនុញ្ញាតឱ្យមានការប្រើប្រាស់កំណត់ហេតុនៃការស្តាប់ចម្លើយដែលជាឯកសារសម្ងាត់នៅក្នុងកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត នៅពេលដែលសហចៅក្រមស៊ើបអង្កេតបានកំណត់ថា ការបង្ហាញឯកសារទាំងនោះនឹងមិនមានហានិភ័យដល់ការស៊ើបអង្កេត ឬ បង្កគ្រោះថ្នាក់ដល់សន្តិសុខរបស់ជនរងគ្រោះ ឬ សាក្សីណាម្នាក់ឡើយ[25]។ នីតិវិធីដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិ មានគោលបំណងការពារអត្តសញ្ញាណរបស់ជនរងគ្រោះ និងសាក្សីនានាដែលត្រូវបានស្តាប់ចម្លើយសម្រាប់កិច្ចស៊ើបសួរក្នុងសំណុំរឿង ០០៣ និង ០០៤ នៅក្នុងវិសាលភាពដែលបានកំណត់ដោយ

[24] សំណើតាមវិធាន ៨៧ កថាខណ្ឌ ៣។ ការដាក់បង្ហាញកំណត់ហេតុរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៤។

[25] ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំបង្ហាញឯកសារនៅក្នុងសំណុំរឿង ០០២ ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១៣ ឯកសារ E127/7/2.2 កថាខណ្ឌ ៧។

សហចៅក្រមស៊ើបអង្កេតអន្តរជាតិ[26]។ នៅក្នុងសេចក្តីសម្រេចកាលពីមុន ពាក់ព័ន្ធនឹងការអនុវត្តចំពោះព័ត៌មានសម្ងាត់ អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់រួចហើយអំពីភាពចាំបាច់ក្នុងការបញ្ចៀសនូវការអាក់ខាននៅក្នុងពេលបំពេញកិច្ចស៊ើបសួរដែលកំពុងដំណើរការនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត[27]។ ដើម្បីរកឃើញនូវតុល្យភាពរវាងការពិភាក្សាលើភ័ស្តុតាងជាសាធារណៈនៅក្នុងសវនាការ និងភាពចាំបាច់ក្នុងការការពារសុចរិតភាពនៃកិច្ចស៊ើបសួរ និងការការពារជនរងគ្រោះ និងសាក្សីពាក់ព័ន្ធនានា អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា វាជាការចាំបាច់ដើម្បីធានាថា ប្រសិនបើចាំបាច់ ព័ត៌មានជាក់លាក់ដែលមានប្រភពចេញមកពីកិច្ចស៊ើបសួរដែលកំពុងតែបន្តដំណើរការនៅក្នុងសំណុំរឿងផ្សេងទៀត នៅតែត្រូវបានរក្សាភាពសម្ងាត់ដដែល នៅពេលមានការពិភាក្សាក្នុងអំឡុងកិច្ចដំណើរការនីតិវិធីជំនុំជម្រះ[28]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងពិចារណាទៅលើចំណុចនេះនៅខាងក្រោម នៅក្នុងសេចក្តីបង្គាប់របស់ខ្លួនទាក់ទងនឹងការប្រើប្រាស់កំណត់ហេតុនៃការស្តាប់ចម្លើយដែលជាឯកសារសម្ងាត់បែបនេះ នៅក្នុងសំណុំរឿង ០០២/០២។

១២. ទោះបីជាអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ការការពារ និងការហាមឃាត់នានាដែលបានស្នើសុំនៅក្នុងនីតិវិធីដែលបានស្នើឡើង មានលក្ខណៈសមស្របក៏ដោយ ក៏អង្គជំនុំជម្រះយល់ផងដែរថា វាជាការចាំបាច់ក្នុងការពិចារណាទៅលើសេចក្តីណែនាំ និងសេចក្តីបង្គាប់ផ្សេងៗទៀតជាធរមានរបស់អង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធនឹងការស្តាប់សក្ខីកម្មរបស់បុគ្គលនានានៅក្នុងសវនាការ[29]។ នីតិវិធីដែលបានកំណត់នៅក្នុងសេចក្តីបង្គាប់ខាងក្រោមនេះ នឹងផ្តល់ឱ្យគ្រប់ភាគីទាំងអស់នូវឱកាសក្នុងការពិភាក្សាដេញដោលទៅលើភ័ស្តុតាងដែលមាននៅចំពោះមុខអង្គជំនុំជម្រះ ក្នុងអំឡុងពេលសវនាការជាសាធារណៈ។ ក្រុម

---

[26] នីតិវិធីដែលបានស្នើឡើង កថាខណ្ឌ ៤-៥។

[27] *សូមមើល* ឧទាហរណ៍ អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង មានចំណងជើងថា "ការផ្ទេរកំណត់ហេតុស្តាប់ចម្លើយសាក្សីក្នុងសំណុំរឿង ០០២ ទៅក្នុងសំណុំរឿង ០០៣ និង ០០៤" ឯកសារ E308/2 ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៤

[28] សូមមើល ផងដែរ អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង មានចំណងជើងថា "ការទទួលយកកំណត់ហេតុស្តាប់ចម្លើយនៅក្នុងសំណុំរឿង ០០៣ និង ០០៤ ពាក់ព័ន្ធនឹងសំណុំរឿង ០០២" ឯកសារ E127/7/2 ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១៣។

[29] សូមមើល ឧទាហរណ៍ សេចក្តីជូនដំណឹងទៅភាគីពាក់ព័ន្ធនឹងនីតិវិធីនៃការកែសម្រួលការសួរសំណួរនិងចម្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំការបំភ្លឺទាក់ទងនឹងការប្រើប្រាស់ឯកសារនានា ក្នុងពេលផ្តល់សក្ខីកម្មរបស់សាក្សី (ឯកសារ E201) ឯកសារ E201/2 ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១២ (ដែលលើកឡើងអំពីការប្រើប្រាស់កំណត់ហេតុស្តាប់ចម្លើយសាក្សីពីមុន របស់ ក.ស.ច.ស ក្នុងអំឡុងកិច្ចដំណើរការនីតិវិធីជំនុំជម្រះ)។

មេធាវីការពារក្ដីមិនបានបង្ហាញថា ការប្រើប្រាស់រហស្សនាម និងលេខឯកសារថ្មី នឹងរារាំង ឬ ប៉ះពាល់ដល់សិទ្ធិក្នុងការការពារក្ដីឡើយ។

១៣. នីតិវិធីដែលបានកំណត់ខាងក្រោមនេះ គឺផ្អែកទៅលើភាពសម្ងាត់នៃកំណត់ហេតុស្ដាប់ចម្លើយ ដែលបានបង្ហាញដោយការិយាល័យសហចៅក្រមស៊ើបអង្កេត។ អង្គជំនុំជម្រះអាចសម្រេចកែប្រែនីតិវិធីនេះ ដោយផ្អែកទៅលើការវិវឌ្ឍដែលពាក់ព័ន្ធណាមួយនៅក្នុងសំណុំរឿង ០០៣ និង ០០៤ ក្នុងករណីចាំបាច់។

**ផ្អែកទៅលើសំអាងហេតុដែលបានបញ្ជាក់ជូនខាងលើ អង្គជំនុំជម្រះសាលាដំបូងសម្រេច ៖**

**ទទួលយក** ឯកសារដែលមានបញ្ជាក់នៅក្នុងសំណើតាមវិធាន ៨៧ ក្នុងឧបសម្ព័ន្ធ ង ធ្វើជាភ័ស្តុតាង។ និង

**បង្គាប់ថា**

ក) ភាគី មេធាវីការពារក្ដី ឬ បុគ្គលផ្សេងទៀត មិនត្រូវលើកយោងដោយផ្ទាល់មាត់ ឬ តាមវិធីផ្សេងពីនេះ ទៅលើកំណត់ហេតុនៃការស្ដាប់ចម្លើយដែលត្រូវបានអនុញ្ញាតឱ្យមានការបង្ហាញនៅក្នុងដីកាសម្រេចលើសំណើសុំដាក់បង្ហាញកំណត់ហេតុស្ដាប់ចម្លើយ ឬ នៅក្នុងការអនុញ្ញាតស្រដៀងគ្នានេះនាពេលក្រោយទៀតពីសហចៅក្រមស៊ើបអង្កេតអន្តរជាតិ នៅក្នុងអំឡុងសវនាការជាសាធារណៈក្នុងសំណុំរឿង ០០២/០២ ថាជាចម្លើយ ឬ ការសម្ភាសន៍ដែលមានប្រភពដើមពីសំណុំរឿង ០០៣ ឬ ០០៤ ឡើយ។

ខ) ភាគី មេធាវីការពារក្ដី ឬ បុគ្គលផ្សេងទៀត មិនត្រូវកំណត់អត្តសញ្ញាណ ឬ បង្ហាញដល់បុគ្គលណាម្នាក់ ឬ អង្គភាពណាមួយ ដែលមិនត្រូវបានអនុញ្ញាតដោយដីកាសម្រេចលើសំណើសុំដាក់បង្ហាញកំណត់ហេតុស្ដាប់ចម្លើយ នូវកំណត់ហេតុនៃការស្ដាប់ចម្លើយទាំងនោះ តាមរយៈកាលបរិច្ឆេទនៃកំណត់ហេតុធ្វើសម្ភាសន៍ ឬ ថាជាចម្លើយ ឬ ថាជាការធ្វើសម្ភាសន៍ដែលមានប្រភពដើមពីសំណុំរឿង ០០៣ ឬ ០០៤ ឡើយ ប៉ុន្តែផ្ទុយទៅវិញ ត្រូវកំណត់អត្តសញ្ញាណនៃកំណត់ហេតុនៃការស្ដាប់ចម្លើយទាំងនេះ ដោយលេខឯកសារក្នុងសំណុំរឿង ០០២ ដែលត្រូវបានកំណត់ បន្ទាប់ពីមានការដាក់បង្ហាញកំណត់ហេតុនៃការស្ដាប់ចម្លើយទាំងនេះនៅក្នុងសំណុំរឿង ០០២ តែប៉ុណ្ណោះ។

គ) គ្រប់ពេលទាំងអស់ក្នុងអំឡុងកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្នុងសំណុំរឿង ០០២/០២ ភាគី មេធាវីការពារក្តី ឬបុគ្គលផ្សេងទៀត ដែលអាន ដកស្រង់ ឬ ប្រើប្រាស់កំណត់ហេតុស្តាប់ចម្លើយ ដែលត្រូវបានអនុញ្ញាតឱ្យមានការដាក់បង្ហាញនៅក្នុងដីកាសម្រេចលើសំណើសុំដាក់បង្ហាញកំណត់ហេតុស្តាប់ចម្លើយ មិនត្រូវបង្ហាញឈ្មោះអ្នកផ្តល់ចម្លើយក្នុងសំណុំរឿង ០០៣ ឬ ០០៤ នៅលើកំណត់ហេតុជាសាធារណៈឡើយ។

ឃ) ភាគី មេធាវីការពារក្តី ឬបុគ្គលផ្សេងទៀត ដែលអាន ដកស្រង់ ឬ ប្រើប្រាស់ កំណត់ហេតុនៃការស្តាប់ចម្លើយ ដែលត្រូវបានអនុញ្ញាតឱ្យមានការដាក់បង្ហាញនៅក្នុងដីកាសម្រេចលើសំណើសុំដាក់បង្ហាញកំណត់ហេតុស្តាប់ចម្លើយ ត្រូវបង្ហាញអត្តសញ្ញាណសាក្សីនៃសំណុំរឿង ០០៣ ឬ ០០៤ បានតែតាមរយៈរហស្សនាមដែលកំណត់ឡើងដោយអង្គជំនុំជម្រះសាលាដំបូងតែប៉ុណ្ណោះសម្រាប់សំណុំរឿង ០០២/០២ ឬ នឹងប្រើប្រាស់តែពាក្យទូទៅប៉ុណ្ណោះ ក្នុងគោលបំណងដើម្បីបញ្ចៀសការកំណត់អត្តសញ្ញាណសាក្សី[30]។ និង

ង) នៅពេលសាក្សី ឬ ដើមបណ្តឹងរដ្ឋប្បវេណីណាម្នាក់ដែលត្រូវផ្តល់សក្ខីកម្មក្នុងសំណុំរឿង ០០២/០២ ទាក់ទងនឹងកំណត់ហេតុនៃការស្តាប់ចម្លើយដែលខ្លួនបានផ្តល់ក្នុងសំណុំរឿង ០០៣ ឬ ០០៤ កំណត់ហេតុនៃការស្តាប់ចម្លើយនោះ ត្រូវបានបង្ហាញអត្តសញ្ញាណត្រឹមតែថាជាកំណត់ហេតុពីមុនរបស់បុគ្គលម្នាក់ ដែលបានផ្តល់ចម្លើយជូនការិយាល័យសហចៅក្រមស៊ើបអង្កេត ប៉ុណ្ណោះ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៤

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE DE PREMIÈRE INSTANCE

**និល ណុន**

[30] អង្គជំនុំជម្រះសាលាដំបូងបានដាក់រហស្សនាមឱ្យបុគ្គលដែលមិនទាន់មានរហស្សនាមនៅក្នុងសំណុំរឿង ០០២/០២ ហើយដែលកំណត់ហេតុនៃការស្តាប់ចម្លើយរបស់បុគ្គលទាំងនោះត្រូវបានទទួលយក អនុលោមតាមសេចក្តីសម្រេចនេះ។ បញ្ជីនៃរហស្សនាម មានភ្ជាប់នឹងសេចក្តីសម្រេចនេះ។